# សហគ្រិនទឹកស្អាតជាស្ត្រីនៅក្នុងប្រទេសកម្ពុជា

## ការពិចារណាអំពីការជួយ និងការប្រឈម ដល់ការផ្តល់អំណាចដល់ស្ត្រី

### ខែមិថុនា ឆ្នាំ២០១៨

## សង្ខេបនៃរបាយការណ៍ស្រាវជ្រាវលេខ៩

> ស្ត្រីអាចបង្ហាញសេចក្តីក្លាហាន ភាពជោគជ័យ និងការចូលរួម នៅក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម និងប្រទេសទាំងមូល - សហគ្រិនទឹកស្អាតជាស្ត្រីកម្ពុជា

របាយការណ៍សង្ខេបនេះ បង្ហាញការរកឃើញ ពីការស្រាវជ្រាវ ដើម្បីពិនិត្យមើលវិសាលភាពដែលភាពជាម្ចាស់ និងការគ្រប់គ្រងរបស់ស្ត្រីលើប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ដែលនាំទៅដល់ការផ្តល់អំណាចដល់ស្ត្រី រួមទាំងការផ្តល់អំណាចផ្នែកសេដ្ឋកិច្ច នៅក្នុងប្រទេសកម្ពុជា។

### សេចក្តីផ្តើម

ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ដែលដំណើរការជាលក្ខណៈឯកជនខ្នាតតូច កំពុងពង្រីកតួនាទីនៅក្នុងតំបន់ជនបទនៃប្រទេសកម្ពុជា ជាពិសេសនៅក្នុងតំបន់ជនបទដែលមានសេដ្ឋកិច្ចរីកលូតលាស់។ ទោះបីយ៉ាងណាក៏ដោយ គេយល់ដឹងតិចតួចអំពីបទពិសោធន៍ផ្សេងៗរបស់បុរស និងស្ត្រីនៅក្នុងវិស័យនេះ ឬក៏ របៀបដែលបទដ្ឋានយេនឌ័រ មានឥទ្ធិពលទៅលើបទពិសោធន៍ និងឱកាសធ្វើជំនួញរបស់ពួកគាត់។

នៅក្នុងឆ្នាំ២០១៥ មានប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតប្រមាណ ៣០០ប្រព័ន្ធ ដែលគ្រប់គ្រងដោយវិស័យឯកជននៅក្នុងតំបន់ជនបទនៃប្រទេសកម្ពុជា ដែលផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋជាង ១លាននាក់ (ធនាគារពិភពលោក ឆ្នាំ២០១៥ ទំព័រទី១៥)។ ក្នុងឆ្នាំថ្មីៗកន្លងមក គោលនយោបាយមួយចំនួនបានដាក់ឲ្យដំណើរការ ដោយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីលើកកម្ពស់សមភាពយេនឌ័រ នៅក្នុងវិស័យទឹកស្អាតនិងអនាម័យ។ គោលនយោបាយមួយ គឺយុទ្ធសាស្ត្រជាតិសម្រាប់ការផ្គត់ផ្គង់ទឹកស្អាតជនបទ (ឆ្នាំ២០១១ – ២០២៥) រួមទាំងការផ្គត់ផ្គង់ដើម្បីពង្រីកសមភាពយេនឌ័រ។ វិធីមួយក្នុងចំណោមវិធីទាំងឡាយ ដែលយុទ្ធសាស្ត្រមានគោលបំណងធ្វើនេះ គឺដោយការបញ្ជ្រាបយេនឌ័រ ក្នុងវិស័យទឹកស្អាតជនបទ (រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០១១ ទំព័រទី១០)។

យ៉ាងណាក៏ដោយ មានការខ្វះចំណេះដឹងសំខាន់ៗ ដែលពាក់ព័ន្ធទៅនឹងរបៀបដែលបទដ្ឋានយេនឌ័រ ទ្រួតស៊ីគ្នាជាមួយវិស័យទឹកស្អាតជនបទ និងជាមួយការរីកចម្រើននៃសហគ្រាសទឹកស្អាត នៅក្នុងប្រទេសកម្ពុជា។ ការខ្វះទាំងនេះ រួមមានការខ្វះចំណេះដឹង អំពីរបៀបដែលយេនឌ័រ មានឥទ្ធិពលលើអ្នកដែលក្លាយខ្លួនជាសហគ្រិនទឹកស្អាត អ្វីដែលជាបទពិសោធន៍ ការប្រឈម និងឱកាសរបស់សហគ្រិន និង របៀបដែលសហគ្រិនភាពទឹកស្អាតមានទំនាក់ទំនងជាមួយការផ្តល់អំណាចដល់ស្ត្រី រួមទាំងការផ្តល់អំណាចផ្នែកសេដ្ឋកិច្ច។

ដើម្បីចាប់ផ្តើមដោះស្រាយការខ្វះចំណេះដឹងទាំងនេះ ការសិក្សានេះបានពិនិត្យមើលវិសាលភាពជាម្ចាស់ និងការគ្រប់គ្រងរបស់ស្ត្រីលើប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ដែលនាំទៅដល់ការផ្តល់អំណាចដល់ស្ត្រី រួមទាំងការផ្តល់អំណាចផ្នែកសេដ្ឋកិច្ច។ ការសិក្សានេះ និងការសិក្សានៅក្នុងប្រទេសឥណ្ឌូនេស៊ី ជាការសិក្សាដំបូង ដើម្បីពិនិត្យមើលជាប្រព័ន្ធនូវបទពិសោធន៍ទាំងឡាយ និងតម្រូវការរបស់សហគ្រិនផ្គត់ផ្គង់ទឹកស្អាតជាស្ត្រី (ចាប់ពីពេលនេះទៅហៅថាសហគ្រិន) និងជាលើកដំបូងដើម្បីពិនិត្យមើលបទពិសោធន៍ ដែលទាក់ទងទៅនឹងក្របខ័ណ្ឌការផ្តល់អំណាចដល់ស្ត្រី។

ការស្រាវជ្រាវនេះបានសហការរវាងវិជ្ជាស្ថានសម្រាប់អនាគតស្ថេរភាព នៃសកលវិទ្យាល័យបច្ចេកវិជ្ជាស៊ីតនី (អាយអេសអេហ្វ យូធីអេស - ISF-UTS) និងអង្គការអ៊ីសមីតវេសត៍ និងសមាគមទឹកស្អាតកម្ពុជា។

គោលបំណងនៃការស្រាវជ្រាវនេះ គឺដើម្បីជម្រាបជូន និងគាំទ្រដល់អង្គការមិនមែនរដ្ឋាភិបាល អ្នកផ្តល់ជំនួយ និងស្ថាប័នរាជរដ្ឋាភិបាលកម្ពុជា ដើម្បីអភិវឌ្ឍន៍បរិស្ថានដែលអំណោយផល (ដូចជាការកសាងសមត្ថភាព) ដែលមើលឃើញយេនឌ័រ អាចគាំទ្រការផ្តល់អំណាចដល់ស្ត្រី និងនឹងផ្តល់វិភាគទានដល់សេវាផ្គត់ផ្គង់ទឹកស្អាតប្រកបដោយចេរភាព នៅតំបន់ជនបទ។ សំណួរទាំងឡាយដែលពាក់ព័ន្ធទៅនឹងការស្រាវជ្រាវនេះ គឺស្ថិតនៅក្នុងប្រអប់ទី១។



រូបភាពទី១. សមាជិកក្រុមស្រាវជ្រាវបានធ្វើសម្ភាសន៍សហគ្រិនផ្គត់ផ្គង់ទឹកស្អាតចំនួន១៥សហគ្រិនជាស្ត្រី នៅក្នុងប្រទេសកម្ពុជា (នេះជារូបភាព១ ក្នុងចំណោមការធ្វើសម្ភាសន៍)

## ប្រអប់ទី១ ៖ សំណួរទាំងឡាយដែលពាក់ព័ន្ធទៅនឹងការស្រាវជ្រាវ

### សំណួរនៃការស្រាវជ្រាវទី ១

តើស្ត្រីត្រូវបានផ្តល់អំណាចអ្វីខ្លះ តាមរយៈនៃការគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតរបស់ពួកគាត់នៅក្នុងប្រទេសកម្ពុជា?

ក. តើអ្វីទៅគឺជាការប្រឈម និងការជួយជារួមសម្រាប់ស្ត្រីជាសហគ្រិន ដើម្បីគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត នៅក្នុងប្រទេសកម្ពុជា? តើការប្រឈម និងការជួយជារួមទាំងនេះ មានទំនាក់ទំនងទៅនឹងការយល់ដឹងអំពីការផ្តល់អំណាចដល់ស្ត្រីយ៉ាងដូចម្តេច?

ខ. តើស្ត្រីចូលរួមអ្វីខ្លះនៅក្នុងការគ្រប់គ្រងសហគ្រាសទឹកស្អាត ក្នុងប្រទេសកម្ពុជា ដើម្បីសម្របសម្រួលការផ្តល់អំណាចដល់ស្ត្រី រួមទាំងការផ្តល់អំណាចផ្នែកសេដ្ឋកិច្ច?

គ. តើអ្វីទៅគឺជាទំនាក់ទំនងរវាងការប្រឈម និងការជួយ ដែលបានជួបប្រទះដោយសហគ្រិនជាស្ត្រី នៅក្នុងវិស័យផ្សេងៗក្នុងប្រទេសកម្ពុជា? តើអ្វីទៅគឺជាការប្រឈម និងការជួយ ដែលបានជួបប្រទះដោយស្ត្រី ដើម្បីគ្រប់គ្រងសហគ្រាសទឹកស្អាត នៅក្នុងប្រទេសកម្ពុជា?

### សំណួរនៃការស្រាវជ្រាវទី ២

តើអ្វីខ្លះត្រូវធ្វើ និងដោយអ្នកណា ដើម្បីគាំទ្រដល់ស្ត្រីជាសហគ្រិនទឹកស្អាត នៅក្នុងប្រទេសកម្ពុជា ដើម្បីសម្រេចការផ្តល់អំណាចដល់ស្ត្រី រួមទាំងការផ្តល់អំណាចផ្នែកសេដ្ឋកិច្ច និងសម្រេចលទ្ធផល?

ក. តើយុទ្ធសាស្ត្រអ្វីខ្លះដែលមានស្រាប់ ដើម្បីគាំទ្រដល់ស្ត្រីជាសហគ្រិនទឹកស្អាត នៅក្នុងប្រទេសកម្ពុជា?

ខ. តើវិធានការអ្វីខ្លះដែលស្ត្រីជាសហគ្រិនទឹកស្អាតត្រូវការ បានគេណែនាំដើម្បីគាំទ្រដល់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតរបស់ពួកគាត់? តើអ្នកណា ដែលពួកគាត់ត្រូវការ ដើម្បីណែនាំនូវវិធានការទាំងនេះ?

គ. តើយុទ្ធសាស្ត្រ និងវិធានការទាំងនេះ គាំទ្រដល់ការត្រូវការ និងតម្រូវការទាំងឡាយ មានន័យសម្រាប់បរិស្ថានដែលអំណោយផល (ដូចជាការកសាងសមត្ថភាព) ក្នុងវិស័យទឹកស្អាតនិងអនាម័យ នៅក្នុងប្រទេសកម្ពុជា ដែលមានទំនាក់ទំនងជាមួយការគាំទ្រសហគ្រិនទឹកស្អាតជាស្ត្រី យ៉ាងដូចម្តេច?

## វិធីសាស្ត្រ

វិធីសាស្ត្រសហការ ត្រូវបានធ្វើសម្រាប់ការស្រាវជ្រាវនេះ ដើម្បីសម្របសម្រួលការចូលរួមរវាងអ្នកធ្វើការស្រាវជ្រាវ និងអ្នកអនុវត្ត។ នេះបានបង្កើតវិធីសាស្ត្រនៃការស្រាវជ្រាវទៅបាន។ ការសិក្សានេះបានទទួលយកវិធីសាស្ត្រនៃគុណភាពជាចំបង ប៉ុន្តែបានបញ្ចូលវិធីសាស្ត្រនៃបរិមាណមួយចំនួន។ ជាសរុប បទសម្ភាសន៍ចំនួន ២៧ ដែលបានគ្រោងឡើង បានធ្វើជាមួយសហគ្រិនទឹកស្អាតជាស្ត្រី សមាជិកក្រុមប្រឹក្សាឃុំ និងអ្នកពាក់ព័ន្ធថ្នាក់ខេត្ត និងថ្នាក់ជាតិ។

ការស្រាវជ្រាវនេះ បានធ្វើនៅខេត្តចំនួនប្រាំបី នៃប្រទេសកម្ពុជា÷ កោះកុង បាត់ដំបង កំពង់ចាម កំពត ព្រះសីហនុ តាកែវ កណ្ដាល និងក្រចេះ។ ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតដែលបានបញ្ចូលក្នុងការសិក្សានេះ មានពី ៦០០ តំណ (៦០០ ខ្នងផ្ទះ) ទៅ ២.៩១០ តំណ (២.៩១០ ខ្នងផ្ទះ)។ ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតទាំងនេះ ស្ថិតនៅតំបន់ជនបទ បានបង្កើតឡើងពីឆ្នាំ២០០១ ដល់ ឆ្នាំ២០១៧។

មគ្គុទ្ទេសក៍សម្ភាសន៍បានផ្តោតលើការប្រឈម និងការជួយ ដើម្បីបង្កើត និងគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងត្រូវបានផ្តល់ពតិមាន ដោយការពិនិត្យឡើងវិញនៃអត្ថបទស្តីពីសហគ្រិនភាពជាស្ត្រី នៅក្នុងប្រទេសកម្ពុជា ឡាវ និងឥណ្ឌូនេស៊ី (លីហ៊ី អ៊ែត អល ឆ្នាំ២០១៧)។ ក្របខ័ណ្ឌនៃការវិភាគ បានប្រើគោលការណ៍ ឬគំនិតទាំងឡាយនៃការផ្តល់អំណាចដល់ស្ត្រី រួមទាំងការផ្តល់អំណាចផ្នែកសេដ្ឋកិច្ច ដែលពិនិត្យមើលការផ្តល់អំណាចជាដំណើរការមួយនៃការផ្លាស់ប្តូរទំនាក់ទំនងខាងអំណាចក្នុងវិធីទាំងឡាយ ដែលលើកកម្ពស់សិទ្ធិស្ត្រី និងយុត្តិធម៌សង្គម។ គោលការណ៍ ឬគំនិតនៃការផ្តល់អំណាច ពិចារណាលើប្រភេទបួននៃអំណាច÷ អំណាចខាងក្នុង អំណាចដើម្បី អំណាចពីលើ និងអំណាចជាមួយ (អេបេន កាបៀ និងខនវ៉ល ឆ្នាំ២០០៨ និង តៃល័រ និងពែសនេត្ទ ឆ្នាំ២០១៤) ដូចដែលបានពិភាក្សាខាងក្រោមនេះ÷




រូបភាពទី២. បទសម្ភាសន៍ទាំងឡាយ បានធ្វើជាមួយអ្នកចូលរួមក្នុងការស្រាវជ្រាវពីប្រាំបីខេត្ត នៅក្នុងប្រទេសកម្ពុជា

## ពតិមានទូទៅពីការរកឃើញ

### ការប្រឈម

សហគ្រិនបានរាយការណ៍ អំពីបួនប្រភេទនៃការប្រឈម ដើម្បីបង្កើត និងគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។ ប្រភេទទាំងនេះមានទំនាក់ទំនងទៅនឹង ÷ ១. បញ្ហាដំណើរការ ២. រាជរដ្ឋាភិបាល និងច្បាប់ ៣. បញ្ហាហិរញ្ញវត្ថុ និង ៤. តម្រូវការសេវាទឹកស្អាតនៅមានការកម្រិត។

ការប្រឈមផ្នែកដំណើរការ រួមមានការបែកធ្លាយទុយោ ដែលកើតឡើងបណ្តាលមកពីការធ្វើផ្លូវថ្នល់ និង

ការធ្វើរបងផ្ទះ ខ្វះការសហការពីប្រជាពលរដ្ឋ (ខ្នងផ្ទះ) និងការមានការកម្រិតចំពោះការធ្វើដំណើរផ្ទាល់ខ្លួនរបស់សហគ្រិន។ ហេដ្ឋារចនាសម្ព័ន្ធដែលបានខូចខាត ដែលបណ្ដាលមកពីការសាងសង់ គឺជាផ្នែកពិសេសមួយនៃកង្វល់របស់សហគ្រិន។

ការអភិវឌ្ឍន៍ផ្លូវថ្នល់បានធ្វើឲ្យខូចទុយោ និងបាត់បង់ទឹក ... ដូច្នេះ យើងមិនអាចផ្គត់ផ្គង់ទឹកស្អាតទៅដល់ខ្នងផ្ទះ ព្រោះទុយោបែកធ្លាយ (សហគ្រិនជាស្ត្រី)។

ការប្រឈមបណ្ដាលមកពីរាជរដ្ឋាភិបាល និងច្បាប់ បានរាយការណ៍ដោយសហគ្រិន រួមទាំងខ្វះគោលនយោបាយ និងច្បាប់ដើម្បីគាំទ្រដល់ការគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ដូចជា ការដាក់កម្រិតថ្លៃទឹក និងរដ្ឋបាលដែលបណ្ដាលឲ្យមានការពិបាក។

ការប្រឈមផ្នែកហិរញ្ញវត្ថុ រួមមានអត្រាការប្រាក់ខ្ពស់ ចំណាយខ្ពស់ទៅលើអគ្គិសនី និងការជួល និងអតិថិជនមិនបានបង់ថ្លៃទាន់ពេល។

បញ្ហាតម្រូវការសេវាទឹកស្អាតនៅមានការកម្រិត រួមមានតម្រូវការទាបពីអតិថិជននៅរដូវវស្សា និងតម្រូវការដែលមានការជឿជាក់ សម្រាប់ការយល់ដឹងរបស់សហគមន៍ បានកើនឡើងអំពីសារៈសំខាន់នៃទឹកស្អាតដែលអាចធ្វើឲ្យមានតម្រូវការសម្រាប់សេវាទឹកស្អាត។

## ការប្រឈមដែលពាក់ព័ន្ធទៅនឹងយេនឌ័រ

ការពិនិត្យឡើងវិញនៃអត្ថបទដែលបានផ្ដល់ពត៌មានអំពីការសិក្សានេះ បានកំណត់ការប្រឈម និងការជួយ សម្រាប់សហគ្រិនជាស្ត្រីក្នុងវិស័យទឹកស្អាតនិងអនាម័យ និងក្នុងវិស័យផ្សេងៗទៀត និងបានរកឃើញផ្នែកសំខាន់ៗចំនួនប្រាំបួននៃការប្រឈមចំបងៗដល់សហគ្រិនភាព (លីហ៊ី អ៊ែត អល ឆ្នាំ២០១៧ និង វិលឡិត អ៊ែត អល ឆ្នាំ២០១៦)៖

១. ច្បាប់
២. ហិរញ្ញវត្ថុ
៣. លទ្ធភាពទទួលបានសេវាអភិវឌ្ឍន៍អាជីវកម្ម នៅមានកម្រិត
៤. តម្លៃនៃវប្បធម៌
៥. បណ្ដាញទំនាក់ទំនង និងការធ្វើបណ្ដាញទំនាក់ទំនង
៦. ការអប់រំ និងការបណ្ដុះបណ្ដាល
៧. តម្លៃមិនផ្លូវការ / អំពើពុករលួយ
៨. ធនធានមនុស្ស
៩. បញ្ហាដំណើរការ

ការស្រាវជ្រាវផ្អែកលើបទពិសោធន៍នៃការសិក្សានេះ បានបញ្ជាក់ថា បញ្ហាដំណើរការ ការប្រឈមផ្នែកច្បាប់ និងបញ្ហាហិរញ្ញវត្ថុ គឺជាការប្រឈមសំខាន់ៗ ចំពោះស្ត្រីដែលគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។ លទ្ធភាពទទួលបានសេវាអភិវឌ្ឍន៍អាជីវកម្មនៅមានកម្រិត តម្លៃនៃវប្បធម៌ (រួមទាំងបទដ្ឋានយេនឌ័រ និងការរើសអើង) ការប្រឈមអំពីធនធានមនុស្ស និងការធ្វើបណ្ដាញទំនាក់ទំនង បានបញ្ជាក់ថា គឺមានការប្រឈមចំណែកខ្លះ។

ទោះបីយ៉ាងណាក៏ដោយ មិនបានបញ្ជាក់ដោយសហគ្រិនទឹកស្អាតទេ ថាជាបញ្ហាចំបងៗ។ ការស្រាវជ្រាវផ្អែកលើបទពិសោធន៍ មិនបានរកឃើញថា កម្រិតនៃការអប់រំ និងការបណ្តុះបណ្តាល ត្រូវបានជឿជាក់ថា ជាការប្រឈមដោយសហគ្រិនឡើយ និងផ្នែកនៃដំណើរការដែលផ្អែកលើបទពិសោធន៍ពីការសិក្សាមិនបានបញ្ជាក់ ឬបញ្ចេញមតិថា តម្លៃមិនផ្លូវការ និងអំពើពុករលួយ បានចាត់ទុកថាជាការប្រឈម។

| ការប្រឈម | អត្ថន័យដែលបានផ្តល់ជូនក្នុងពេលធ្វើបទសម្ភាសន៍ | ការប្រឈមដែលវាយតម្លៃដោយសហគ្រិន ទៅតាមលំដាប់នៃភាពសំខាន់ |
|---|---|---|
| បញ្ហាដំណើរការ | រួមមានការចំណាយខ្ពស់ ដូចជាអគ្គិសនី ការជួល។ល។ លទ្ធភាពទទួលបានប្រភពទឹកមិនទៀងទាត់ និងមិនគ្រប់គ្រាន់ពេញមួយឆ្នាំ និងឧបករណ៍ខូច។ | ១ |
| បញ្ហារាជរដ្ឋាភិបាល និងច្បាប់ | រួមមានតម្រូវការរបស់រាជរដ្ឋាភិបាល ដើម្បីបង់ថ្លៃ ឬពន្ធ គោលនយោបាយដែលធ្វើឱ្យពិបាកដល់ការដំណើរការសហគ្រាសទឹកស្អាត ខ្វះការគាំទ្រពីរាជរដ្ឋាភិបាល និងវិធីសាស្ត្រឧបត្ថម្ភធនមិនស្របគ្នា។ | ១ |
| បញ្ហាហិរញ្ញវត្ថុ | រួមមានការខ្វះជម្រើសហិរញ្ញវត្ថុសម្រាប់សហគ្រិន ឬអតិថិជន អត្រាការប្រាក់ខ្ពស់ អតិថិជនមិនបានបង់ថ្លៃទាន់ពេល និងការប្រឈមដើម្បីសម្រេចដល់សេដ្ឋកិច្ចកម្រិតកំពូល (មានតម្រូវការខ្ពស់ ផលិតបានច្រើន លក់បានច្រើន មានតម្លៃថោក ប៉ុន្តែជាសរុបចំណេញបានច្រើន - economies of scale) ជាពិសេសនៅតំបន់ដាច់ស្រយាល។ | ២ |
| តម្រូវការសេវាទឹកស្អាតនៅមានការកម្រិត | រួមមានតម្រូវការទាប និងមិនទៀងទាត់ ដែលអាចបណ្តាលមកពីភាពខុសគ្នាទៅតាមរដូវក្នុងការផ្គត់ផ្គង់ទឹក ឬតម្រូវការ និងខ្វះពត៌មានអំពីអតិថិជនដែលជាសក្តានុពល និងតម្រូវការរបស់ពួកគាត់។ | ២ |
| ការប្រឈមអំពីធនធានមនុស្ស | រួមមានលទ្ធភាពទទួលបានជំនាញអាជីវកម្ម និងបច្ចេកទេសតិចតួច ឬក៏គ្មាន ពិបាករកបុគ្គលិកដែលមានជំនាញដែលអ្នកត្រូវការ មិនមានពេលគ្រប់គ្រាន់ដើម្បីគ្រប់គ្រងសហគ្រាសទឹកស្អាតរបស់អ្នក។ | ២ |
| បទដ្ឋានវប្បធម៌ និងការរំពឹងទុក | រួមមានឯករាជសេដ្ឋកិច្ចបានកាត់បន្ថយ និង/ ឬ ឱកាសដើម្បីសម្រេចលំនឹងហិរញ្ញវត្ថុ ការរំពឹងទុកថាអ្នកនឹងនៅផ្ទះ និងមើលថែទាំគ្រួសារប្រសើរជាងធ្វើការយកប្រាក់ មិនបានទទួលការគាំទ្រ (ឬ អនុញ្ញាត) ឱ្យធ្វើដំណើរ និងការមានទស្សនៈថាស្ត្រីមានស្ថានភាពទាបជាងបុរស។ | ៣ |
| លទ្ធភាពទទួលបានបណ្តាញទំនាក់ទំនង | រួមមានការប្រឈមដល់ឱកាសនៃការធ្វើបណ្តាញទំនាក់ទំនងដែលជួយគាំទ្រដល់សកម្មភាពអាជីវកម្មរបស់អ្នក។ | ៤ |

| | | |
|---|---|---|
| ការអប់រំ និងការបណ្តុះបណ្តាល | រួមមានការមានកម្រិតទាបនៃអក្ខរកម្ម (ការចេះអាននិងសរសេរ) ធៀបទៅនឹងបុរស មានការគាំទ្រតិចដើម្បីទៅរៀននៅសាលា ឬ ទៅមហាវិទ្យាល័យ និងឱកាសទទួលការបណ្តុះបណ្តាល។ | ៥ |

តារាងទី១. ការប្រឈមដែលវាយតម្លៃដោយសហគ្រិន ទៅតាមលំដាប់នៃភាពសំខាន់ៗ

(ផ្អែកនៃដំណើរការដែលផ្អែកលើបទពិសោធន៍ពីការស្រាវជ្រាវ។ អ៊ិន = ១៥)

## ការជួយ

សហគ្រិនបានរាយការណ៍អំពីការជួយសំខាន់ៗចំនួនបី ដែលបានជួយពួកគាត់ដើម្បីបង្កើត និងគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត÷ ១. ការជួយផ្នែកសង្គម ២. ការជួយផ្នែកសេដ្ឋកិច្ច និង ៣. ការជួយផ្នែកកម្មវិធី។ ការជួយផ្នែកសង្គម រួមមានការទទួលបានការលើកទឹកចិត្ត និងការជួយអនុវត្តពីសមាជិកគ្រួសារ និងមិត្តភ័ក្តិ ក៏ដូចជាការមើលឃើញស្ត្រីដទៃបានទទួលជោគជ័យនៅក្នុងវិស័យទឹកស្អាត។ ការជួយផ្នែកសេដ្ឋកិច្ច រួមមានលទ្ធភាពទទួលបានហិរញ្ញវត្ថុ រួមទាំងកម្ចីពីស្ថាប័នហិរញ្ញវត្ថុ ឬសមាជិកគ្រួសារ។ ការជួយផ្នែកកម្មវិធី បានផ្តល់ដោយសមាគមទឹកស្អាតកម្ពុជា និងស្ថាប័នរាជរដ្ឋាភិបាល ដូចជាមន្ទីរឧស្សាហកម្មនិងសិប្បកម្មខេត្ត និងការជួយផ្នែកកម្មវិធីទាំងនេះបានកំណត់ដោយសហគ្រិនថាមានប្រយោជន៍ធំណាស់។

ខ្ញុំបានទទួលការបណ្តុះបណ្តាលពីមន្ទីរឧស្សាហកម្មនិងសិប្បកម្មខេត្ត អំពីរបៀបសម្អាតអាងចម្រោះទឹកស្អាត របៀបរកឲ្យឃើញកន្លែងធ្លាយ ឬជ្រាបនៅក្នុងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងការគ្រប់គ្រងផ្នែករដ្ឋាបាល (សហគ្រិន)។

## លទ្ធផលនៃការផ្តល់អំណាច

វិសាលភាពដែលធ្វើជាម្ចាស់ និងការគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត បានសម្របសម្រួលការផ្តល់អំណាចដល់សហគ្រិន រួមទាំងការផ្តល់អំណាចផ្នែកសេដ្ឋកិច្ច ត្រូវបានធ្វើការវិភាគដោយប្រើគោលការណ៍ ឬគំនិត លើប្រភេទបួននៃអំណាច÷ អំណាចខាងក្នុង អំណាចដើម្បី អំណាចពីលើ និងអំណាចជាមួយ (អេបេនកាបៀ និងខនវ៉ល ឆ្នាំ២០០៨ និង តៃល័រ និងពែសនេតូ ឆ្នាំ២០១៤)។ **អំណាចខាងក្នុង** សំណូមពរថាស្ត្រីមានអំណាចពេញលេញ និងបានទទួលនូវការផ្តល់អំណាចដោយខ្លួនឯងពីខាងក្នុងខ្លួន នៅពេលពួកគាត់មានជំនឿទៅលើតម្លៃ និងសមត្ថភាពខ្លួនឯង អារម្មណ៍ដែលពួកគាត់ត្រូវទទួលបានដើម្បីមានសិទ្ធិដែលគេគោរព និងជំនឿលើខ្លួនឯងដែលត្រូវការ ដើម្បីធ្វើការផ្លាស់ប្តូរនៅក្នុងជីវិត។ ចំណែកឯ សហគ្រិនភាគច្រើននៅក្នុងការសិក្សានេះ បានបង្ហាញសមាសភាគនៃអំណាចខាងក្នុង ចំពោះការយល់ឃើញនៃការមានសមត្ថភាពដូចបុរសដើម្បីគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត (អ៊ិន = ១០ នៃ ១៥) ជំនឿលើខ្លួនឯងដើម្បីចាប់ផ្តើមប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត (អ៊ិន = ២ នៃ ១៥) បទដ្ឋានសង្គម និងការយល់ឃើញដែលលើកកម្ពស់បុរសថា អាចធ្វើដំណើរទៅឆ្ងាយពីផ្ទះ និងជាអ្នកធ្វើការងារខ្លាំងក៏ត្រូវបានគេនិយាយផងដែរ។

វាមានភាពខុសគ្នារវាងបុរសនិងស្ត្រីក្នុងការបង្កើតសេវាទឹកស្អាត ... បុរសមិនធ្វើការងារផ្ទះបានច្រើនដូចស្ត្រីទេ និងបុរសមានចំណេះដឹងច្រើនជាងស្ត្រី ... បុរសធ្វើការងារលឿនជាងស្ត្រី និងវាមានភាពងាយស្រួលចំពោះបុរសដើម្បីទៅធ្វើការងារខាងក្រៅ និងធ្វើការងារនៅពេលយប់ ឧ. ទុយោធ្លាយ ឬបែក (សហគ្រិនជាស្ត្រី)។

ចំណែកឯ សហគ្រិនទាំងឡាយបានរាយការណ៍អំពីផលប្រយោជន៍ ពីការបណ្តុះបណ្តាលដែលបានផ្តល់ដោយអង្គការជាច្រើន និងបានរាយការណ៍ថា ការបណ្តុះបណ្តាលនេះបានសម្របសម្រួលការផ្តល់អំណាចផ្នែកសេដ្ឋកិច្ច និងការប្រុងប្រៀបដើម្បីចាប់ផ្តើមអាជីវកម្ម ពួកគេក៏បានបញ្ជាក់អំពីតម្រូវការការបណ្តុះបណ្តាលដែលបានកំណត់បន្ថែម និងបន្តទៀត។

**អំណាចដើម្បី** គឺពាក់ព័ន្ធទៅនឹងស្ត្រីមានអារម្មណ៍ពេញដោយអំណាច និងទទួលបានការផ្តល់អំណាចដើម្បីកាន់តួនាទីធ្វើការសម្រេចចិត្តនៅក្នុងផ្ទះ សហគមន៍ និងសេដ្ឋកិច្ច និងគ្រប់គ្រងការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុ នៅក្នុងសហគ្រាសរបស់ខ្លួន។ សហគ្រិនទាំងឡាយបានរាយការណ៍ថា មានអំណាចដើម្បីគ្រប់គ្រងការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុ និងមានឯករាជ្យច្រើនឡើង រួមទាំងឯករាជ្យផ្នែកហិរញ្ញវត្ថុ។ សហគ្រិនទាំងអស់បានចូលរួមក្នុងតួនាទីធ្វើការសម្រេចចិត្តដែលពាក់ព័ន្ធទៅនឹងការចំណាយក្នុងផ្ទះ និងសហគ្រិនភាគច្រើនក៏បានរាយការណ៍អំពីការគ្រប់គ្រងហិរញ្ញវត្ថុ នៃប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត (អ៊ិន = ១០ នៃ ១៥)។

ខ្ញុំមានជំនឿក្នុងការគ្រប់គ្រងហិរញ្ញវត្ថុនៃអាជីវកម្មរបស់ខ្ញុំ ព្រោះចំណូល និងចំណាយរបស់ខ្ញុំមិនអីទេ ... ខ្ញុំចង់ឲ្យស្ត្រីកុំពឹងទៅលើតែប្តីរបស់ខ្លួន (សហគ្រិនជាស្ត្រី)។

ភាគច្រើននៃប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតដែលបានពិនិត្យមើលនៅក្នុងការសិក្សានេះ គឺជាអាជីវកម្មគ្រួសារដែលប្តី និងសមាជិកគ្រួសារ ក៏បានដើរតួនាទីសំខាន់នៅក្នុងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុ រួមគ្នា គឺជារឿងធម្មតា។

**អំណាចពីលើ** គឺពាក់ព័ន្ធទៅនឹងស្ត្រីមានអារម្មណ៍ថា ពួកគាត់កាន់កាប់ និងមានលទ្ធភាពទទួលបានធនធានជាចំណេះដឹង រូបវ័ន្ត និងហិរញ្ញវត្ថុ។ ចំណែកឯ សហគ្រិនទាំងឡាយបានរាយការណ៍ថា មានជំនឿក្នុងការគ្រប់គ្រងហិរញ្ញវត្ថុរបស់សហគ្រាសរបស់ខ្លួន ពួកគាត់បានមានកង្វល់អំពីអត្រាការប្រាក់ខ្ពស់ លទ្ធភាពទទួលបានហិរញ្ញវត្ថុ សេរីភាពក្នុងការធ្វើដំណើរ និងតម្រូវការរបស់ពួកគាត់ សម្រាប់ការបណ្តុះបណ្តាលបច្ចេកទេសបន្ថែម។ អត្រាការប្រាក់ខ្ពស់នៃប្រាក់កម្ចីបានដកចេញ បន្ទុកទ្វេនៃការងារ (ដូចជាការងារផ្ទះ និងការធ្វើជំនួញ) បានរាយការណ៍ដោយសហគ្រិនមួយចំនួន និងកង្វល់អំពីស្ថានភាពហិរញ្ញវត្ថុនៃសហគ្រាសរបស់ពួកគាត់ ការផ្តល់អំណាចផ្នែកសេដ្ឋកិច្ចសម្រាប់ស្ត្រី គឺនៅមានកម្រិត។

> ខ្ញុំមិនទាន់បានចំណេញប្រាក់ទេ ព្រោះខ្ញុំបន្តចំណាយប្រាក់ទៅលើទុយោសម្រាប់ពង្រីកបណ្តាញ សម្រាប់កម្មករដើម្បីជីក និងដាក់ទុយោ និទៅលើសម្ភារៈ និងឧបករណ៍ ... ខ្ញុំមិនទាន់មានជំនឿ ព្រោះចំណាយច្រើនជាងចំណូល (សហគ្រិន)។

**អំណាចជាមួយ** គឺពោលទៅដល់សមត្ថភាពដើម្បីសហការជាមួយស្ត្រីដទៃទៀត ក្នុងដំណើរការចលនាជាក្រុម ដើម្បីទាមទារសិទ្ធិដែលត្រូវបានការពារ និងដើម្បីផ្លាស់ប្តូរលក្ខខ័ណ្ឌទីផ្សារ និងការងារសម្រាប់ស្ត្រី។ សហគ្រិនមួយចំនួន បានរាយការណ៍ អំពីបទពិសោធន៍នៃអំណាចជាមួយសហគ្រិនដទៃ។ ពួកគាត់បាននិយាយថា នេះបានឲ្យផលក្នុងការគាំទ្រស្ត្រីទៅវិញទៅមក ដើម្បីបង្កើតប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។

> ខ្ញុំបានឃើញស្ត្រីដទៃធ្វើជំនួញនេះ ហើយខ្ញុំស្រឡាញ់វាដែរ ... បន្ទាប់មកខ្ញុំបានសិក្សាទីតាំង ខ្ញុំបានប្រមូលទិន្នន័យ ខ្ញុំបានទំនាក់ទំនងជាមួយមេឃុំដើម្បីប្រឹក្សាជាមួយគាត់ (សហគ្រិន)។

សហគ្រិនទាំងឡាយក៏បានបង្ហាញចំណង់ ដើម្បីជួយស្ត្រីដទៃបង្កើតសហគ្រាសទឹកស្អាត បើពួកគាត់បានចាប់អារម្មណ៍ និងបានទទួលពត៌មាន និងការគាំទ្រផ្នែកហិរញ្ញវត្ថុ។

> វាជាជម្រើសមួយដ៏ល្អណាស់សម្រាប់ស្ត្រីដើម្បីធ្វើជំនួញទឹកស្អាត ... ខ្ញុំនឹងផ្តល់ការណែនាំដល់គាត់ បើគាត់ចាប់អារម្មណ៍ក្នុងការបង្កើតសេវាទឹកស្អាត (សហគ្រិន)។

## ការធ្វើឲ្យប្រសើរឡើងផ្នែកបរិស្ថានដែលអំណោយផលសម្រាប់សហគ្រិនជាស្ត្រី: យន្តការគាំទ្រ

ការធ្វើការវិភាគរបស់យើងទៅលើការប្រឈម ការជួយ ការផ្តល់អំណាច រួមទាំងការផ្តល់អំណាចផ្នែកសេដ្ឋកិច្ច និងលទ្ធផលទាំងឡាយ បានធ្វើឲ្យទៅរួចចំពោះភាពជាដៃគូក្នុងការធ្វើការស្រាវជ្រាវនេះ ដើម្បីធ្វើជាអនុសាសន៍សម្រាប់អ្នកពាក់ព័ន្ធទាំងឡាយ ដែលជាផ្នែកនៃបរិស្ថានដែលអំណោយផលសម្រាប់ការផ្គត់ផ្គង់ទឹកស្អាតជនបទ នៅក្នុងប្រទេសកម្ពុជា។ អនុសាសន៍ទាំងនេះត្រូវបានជម្រាបជូនតាមការឆ្លើយតបពីសហគ្រិនទាំងឡាយ ដែលត្រូវបានគេសួរ អំពីយន្តការគាំទ្រអ្វីខ្លះដែលពួកគាត់រកឃើញថា មានប្រយោជន៍បំផុត ដើម្បីផ្តោតទៅលើការប្រឈមទាំងឡាយដែលពួកគាត់បានជួបប្រទះ។ សហគ្រិនទាំងឡាយបានកំណត់តម្រូវការសម្រាប់ការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុបន្ថែមទៀត ការអប់រំសម្រាប់សហគមន៍អំពីផលប្រយោជន៍នៃទឹកស្អាត (ដើម្បីបង្កើនតម្រូវការទឹកស្អាត) លទ្ធភាពទទួលបាននូវបណ្តាញគាំទ្រជាស្ត្រី និងស្ត្រីដូចគ្នា និងឧបត្ថម្ភធនដល់គ្រួសារក្រីក្រ និង តំបន់ដាច់ស្រយាល ដើម្បីតភ្ជាប់ទៅប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតរបស់ពួកគាត់។ សហគ្រិនទាំងឡាយបានកំណត់ថា សមាគមទឹកស្អាតកម្ពុជា ទីភ្នាក់ងាររាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងគ្រួសារទាំងឡាយ ជាអង្គភាពមានតួនាទីដ៏សំខាន់បំផុត ដើម្បីផ្តល់ការគាំទ្រទាំងនេះដល់ពួកគាត់។



សហគ្រិនជាស្ត្រីពន្យល់អំពីទីតាំងប្រភពទឹកដែលទទួលទឹកមកសម្រាប់សហគ្រាសទឹកស្អាតរបស់គាត់។

## សង្ខេបនៃការរកឃើញ និងអនុសាសន៍

ការផ្លាស់ប្តូរនៃទំនាក់ទំនងអំណាចក្នុងវិធីទាំងឡាយដែលលើកកម្ពស់សមភាព និងសិទ្ធិស្ត្រី និងការស្ទាបស្ទង់ថា តើការផ្លាស់ប្តូរ ពិតជាធ្វើឲ្យប្រសើរឡើងនូវលក្ខខណ្ឌសម្រាប់ស្ត្រី គឺជាការប្រឈមស្មុកស្មាញ។ ចំណែកឯការចូលរួមរបស់ស្ត្រីក្នុងវិស័យទឹកស្អាត អាចសម្របសម្រួលការផ្តល់អំណាចសម្រាប់ពួកគាត់ រួមទាំងការផ្តល់អំណាចផ្នែកសេដ្ឋកិច្ច ការស្រាវជ្រាវនេះបានបង្ហាញថា ដើម្បីធ្វើឲ្យប្រសើរឡើងនូវលទ្ធផលនៃការផ្តល់អំណាចសម្រាប់ស្ត្រី នៅក្នុងតំបន់ជនបទនៃប្រទេសកម្ពុជា គឺត្រូវមានតម្រូវការសម្រាប់ការគាំទ្របន្ថែម ដើម្បីផ្តោតទៅលើបន្ទុកទ្វេនៃការងាររបស់ស្ត្រីនៅក្នុងផ្ទះ និងនៅក្នុងសហគ្រាស ដើម្បីធ្វើឲ្យប្រសើរឡើងនូវលទ្ធភាពទទួលបានការបណ្តុះបណ្តាលផ្នែកបច្ចេកទេស ដើម្បីធ្វើឲ្យប្រសើរឡើងនូវលទ្ធភាពទទួលបានឥណទានមានអត្រាការប្រាក់ទាប និងលើកកម្ពស់បណ្តាញគាំទ្រស្ត្រី និងស្ត្រីដែលមានវិជ្ជាជីវៈដូចគ្នា។

ការស្រាវជ្រាវនេះ បានបង្ហាញនូវការរកឃើញសំខាន់ៗ និងអនុសាសន៍ចំនួនប្រាំបី សម្រាប់អ្នកផ្តល់ជំនួយ អង្គការសង្គមស៊ីវិល និងស្ថាប័នរាជរដ្ឋាភិបាល នៅក្នុងប្រទេសកម្ពុជា (ថ្នាក់ឃុំ ខេត្ត និងជាតិ)៖

១. ចំណែកឯ **កាប្រឈមដែលពាក់ព័ន្ធទៅនឹងបទដ្ឋានយេនឌ័រ** មិនត្រូវបានពិចារណាដោយសហគ្រិនថា ជាការប្រឈមធំបំផុតទេ សេរីភាពក្នុងការធ្វើដំណើរមានកម្រិតសម្រាប់ស្ត្រី (ការលំបាកធ្វើដំណើរឆ្ងាយពីផ្ទះ និងការចេញពីផ្ទះនៅពេលយប់) និងកិច្ចការផ្ទះ ត្រូវបានរាយការណ៍ថា ជាកង្វល់។ កាប្រឈមដែលពាក់ព័ន្ធទៅនឹងបន្ទុកការងារ និងសេរីភាពក្នុងការធ្វើដំណើរទាំងនេះ បានធ្វើឲ្យកាន់តែពិបាកសម្រាប់សហគ្រិនជាស្ត្រីដើម្បីគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតរបស់ពួកគាត់ និងបានរារាំងការចូលរួមរបស់ស្ត្រីក្នុងការប្រជុំ ក៏ដូចជាសមត្ថភាពរបស់ពួកគាត់ដើម្បីឆ្លើយតបទៅនឹងបញ្ហាដំណើរការ ដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។

**អនុសាសន៍៖** អ្នកផ្តល់ជំនួយ អង្គការសង្គមស៊ីវិល និងស្ថាប័នរាជរដ្ឋាភិបាល គួរតែអភិវឌ្ឍន៍ទៅលើការយល់ដឹងនៃភាពផ្សេងៗគ្នាផ្នែកយេនឌ័រ និងការប្រឈមទាំងឡាយ ក្នុងកម្មវិធីរបស់ខ្លួន ដើម្បីឲ្យបទដ្ឋាន

ទាំងឡាយនៃយេនឌ័រ ដែលមានឥទ្ធិពលលើសេរីភាពក្នុងការធ្វើដំណើរ បន្ទុកការងារផ្ទះ និងពេលវេលាមានកម្រិត (ជាឧទាហរណ៍) ត្រូវបានគេគិតគូរ និងគ្រប់គ្រងយ៉ាងយកចិត្តទុកដាក់។ ការអនុវត្តបន្តនៃការពិនិត្យមើលភាពផ្សេងៗគ្នាផ្នែកយេនឌ័រដោយអ្នកផ្តល់ជំនួយ អង្គការសង្គមស៊ីវិល និងស្ថាប័នរាជរដ្ឋាភិបាល នឹងជួយជម្រាបអំពីគោលនយោបាយ និងកម្មវិធី។

២. **ការប្រឈមផ្នែកដំណើរការ** ត្រូវបានវាយតម្លៃថា ជាការប្រឈមមួយយ៉ាងខ្ពស់ (បន្ថែមជាមួយការប្រឈមបណ្តាលមកពីរាជរដ្ឋាភិបាល និងច្បាប់) ដែលសហគ្រិនជួបប្រទះ នៅពេលធ្វើអាជីវកម្មទឹកស្អាតរបស់ពួកគាត់។ ការប្រឈមផ្នែកដំណើរការ រួមមានការចំណាយខ្ពស់ ដូចជាអគ្គិសនី និងការជួល ធ្លាយឬជ្រាប និងបែកទុយោទឹក និងខូចឧបករណ៍។

**អនុសាសន៍÷** បង្កើនទំនាក់ទំនងរវាងផ្នែកផ្សេងៗនៃរាជរដ្ឋាភិបាល និងសហគ្រិនអំពីការសាងសង់ដែលអាចធ្វើឱ្យខូចទុយោទឹក/បង្អាក់សេវា។ ក្រៅពីនេះ ការគាំទ្រត្រូវបានធានាសម្រាប់ការសិក្សាលទ្ធភាពមានលក្ខណៈជំនាញ ដើម្បីឱ្យសហគ្រិនទាំងឡាយអាចជួលក្រុមហ៊ុនដែលមានគុណភាព ដើម្បីធ្វើការសិក្សាលទ្ធភាព ដើម្បីកំណត់ទីតាំងដែលល្អបំផុតសម្រាប់ប្រភពទឹក និងអាងចម្រោះទឹកស្អាត និងធ្វើផែនការអំពីប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតរបស់ពួកគាត់ដ៏ល្អបំផុត។

៣. **ការប្រឈមបណ្តាលមកពីរាជរដ្ឋាភិបាល និងច្បាប់** ត្រូវបានវាយតម្លៃថា ជាការប្រឈមមួយយ៉ាងខ្ពស់ ដែលសហគ្រិនជួបប្រទះ នៅពេលធ្វើអាជីវកម្មទឹកស្អាតរបស់ពួកគាត់។ សហគ្រិនទាំងឡាយបានរាយការណ៍ថា ការកម្រិតផ្នែកគោលនយោបាយ និងច្បាប់ រួមទាំងការកម្រិតលើតម្លៃទឹក ការទំនាក់ទំនងមិនបានគ្រប់គ្រាន់អំពីការសាងសង់ និងគោលនយោបាយសំណងមិនបានគ្រប់គ្រាន់ចំពោះការខូចខាតទុយោទឹក ដែលបណ្តាលមកពីការធ្វើផ្លូវថ្នល់ (ជាឧទាហរណ៍)។ ភ្នាក់ងារពាក់ព័ន្ធទាំងឡាយរបស់រាជរដ្ឋាភិបាល មិនបានវាយតម្លៃការប្រឈមនេះថាខ្ពស់ទេ មិនដូចសហគ្រិនទាំងឡាយទេ នេះបង្ហាញថា ភ្នាក់ងារពាក់ព័ន្ធទាំងឡាយរបស់រាជរដ្ឋាភិបាល ប្រហែលជាមិនបានដឹងអំពីការប្រឈមទាំងឡាយ ដែលសហគ្រិនជួបប្រទះដែលពាក់ព័ន្ធទៅនឹងគោលនយោបាយ និងច្បាប់របស់រាជរដ្ឋាភិបាល។

**អនុសាសន៍÷** អង្គការសង្គមស៊ីវិល និងសមាគមទាំងឡាយ អាចធ្វើឱ្យមានការគាំទ្រពីរាជរដ្ឋាភិបាល នូវតម្រូវការរបស់សហគ្រិនទាំងឡាយ ដើម្បីឱ្យការប្រឈមទាំងឡាយប្រចាំថ្ងៃ ត្រូវបានយល់ដឹង និងឆ្លើយតប។ នេះអាចរួមមានការសុំឱ្យរាជរដ្ឋាភិបាលធ្វើការអភិវឌ្ឍន៍គោលនយោបាយស្តីពីសំណង និងការទំនាក់ទំនងចំពោះការខូចខាតទុយោទឹក និងការបង្អាក់សេវា ដែលបណ្តាលមកពីការធ្វើផ្លូវថ្នល់។

៤. **ការប្រឈមផ្នែកហិរញ្ញវត្ថុ** ត្រូវបានកំណត់ថាជាការប្រឈមលេខពីរចំពោះសហគ្រិនទាំងឡាយ (បន្ថែមជាមួយតម្រូវការមានកម្រិតសម្រាប់សេវាទឹកស្អាត)។ នៅក្នុងករណីភាគច្រើន សហគ្រិនទាំឡាយបានរាយការណ៍ថា ពួកគាត់មិនទាន់មានប្រាក់ចំណេញទេ (កំណត់សំគាល់ថា មានប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតចំនួនប្រាំក្នុងចំណោមប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតទាំងនេះ បានបង្កើតឡើងតិចជាងប្រាំឆ្នាំ)។ អត្រាការប្រាក់ខ្ពស់ ត្រូវបានកំណត់ជាបញ្ហាពិសេសមួយ ហើយសហគ្រិនទាំងឡាយបាននិយាយថា ពួកគាត់ចង់បានការគាំទ្រដើម្បីទទួល

បានកម្ចីដែលមានអត្រាការប្រាក់ទាប និងឧបត្ថម្ភធនដើម្បីតភ្ជាប់ទៅតំបន់ដាច់ស្រយាលក្នុងតំបន់សេវារបស់ពួកគាត់។

**អនុសាសន៍÷** សម្របសម្រួលការណែនាំផ្នែកហិរញ្ញវត្ថុ និងការគាំទ្រសម្រាប់សហគ្រិនទាំងឡាយ ដើម្បីទទួលបានកម្ចីដែលមានអត្រាការប្រាក់ទាប ដែលស្របទៅនឹងបរិបទទាំងឡាយនៃប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។ អង្គការសង្គមស៊ីវិល/អ្នកផ្តល់ជំនួយ/ស្ថាប័នរាជរដ្ឋាភិបាល អាចជួយឱ្យមានការផ្តល់ហិរញ្ញវត្ថុជាមុន (ដើម្បីបង្កើតប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងផ្តល់សេវាជាពិសេសដល់តំបន់ដាច់ស្រយាល) និងដើម្បីអភិវឌ្ឍន៍គំនិតថ្មីផ្នែកហិរញ្ញប្បទាន (គឺថា: កម្ចីដែលមានអត្រាការប្រាក់ទាប និងជម្រើសធនាគារផ្នែកសង្គម)។ ក៏ត្រូវអប់រំ និងគាំទ្រសហគ្រិនទាំងឡាយដើម្បីយល់ដឹងបានប្រសើរឡើងនូវផលប្រយោជន៍ និងហានិភ័យនៃហិរញ្ញវត្ថុសម្រាប់សហគ្រាសទឹកស្អាត ដើម្បីឱ្យការរំពឹងទុករបស់ពួកគាត់ពីកម្រិតចំណេញ និងការទទួលមកវិញនូវប្រាក់ដើមទុន គឺប្រាកដ។

៥. **តម្រូវការសេវាទឹកស្អាតនៅមានការកម្រិត** ក៏ត្រូវបានកំណត់ថា ជាការប្រឈមលេខពីរ ដែលសហគ្រិនទាំងឡាយជួបប្រទះ នៅពេលគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតរបស់ពួកគាត់។ បញ្ហាទាំងឡាយដែលពាក់ព័ន្ធទៅនឹងការចូលទីផ្សារ រួមមានតម្រូវការទាប និងមិនទៀងទាត់សម្រាប់ទឹកស្អាតបណ្តាលមកពីការប្រែប្រួលតាមរដូវកាល និងការប្រឈមផ្សេងៗទៀត រួមទាំងតម្លៃខ្ពស់ នៃការតបណ្តាញទៅតំបន់ជនបទ។

**អនុសាសន៍÷** យុទ្ធនាការនៃការអប់រំសហគមន៍ស្តីពីផលប្រយោជន៍នៃទឹកស្អាត និងការតទឹកតាមខ្នងផ្ទះពីប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត (សម្រាប់សុខភាព និងភាពងាយស្រួល) គឺត្រូវការដើម្បីបង្កើនតម្រូវការសម្រាប់សេវាទឹកស្អាត និងដើម្បីគាំទ្រសហគ្រិនទាំងឡាយឱ្យសម្រេចដល់សេដ្ឋកិច្ចកម្រិតកំពូល (មានតម្រូវការខ្ពស់ ផលិតបានច្រើន លក់បានច្រើន មានតម្លៃថោក ប៉ុន្តែជាសរុបចំណេញបានច្រើន)។ អង្គការសង្គមស៊ីវិល/ស្ថាប័នរាជរដ្ឋាភិបាល អាចផ្តល់ការគាំទ្រដល់តំបន់ដាច់ស្រយាល ដើម្បីតទឹកតាមខ្នងផ្ទះពីប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ដើម្បីជួយសហគ្រិនទឹកស្អាតតទឹកឱ្យប្រជាពលរដ្ឋបានច្រើន និងធ្វើឱ្យការពង្រីកប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតអាចទទួលជោគជ័យផ្នែកហិរញ្ញវត្ថុ។ ជម្រើសជាច្រើនផ្នែកហិរញ្ញវត្ថុអាចត្រូវបានពិចារណា ដូចជាជំនួយផ្អែកលើលទ្ធផល និងហិរញ្ញប្បទានសម្រាប់ការពង្រីកទុយោមេ ក៏ដូចជាការសិក្សាលទ្ធភាពសម្រាប់ដំណោះស្រាយតាមបែបវិមជ្ឈការដទៃទៀត។

៦. **ការបណ្តុះបណ្តាល និងការគាំទ្របច្ចេកទេស** ត្រូវបានកំណត់ដោយសហគ្រិនទាំងឡាយ ជាតម្រូវការធំបំផុត (ផ្នែកនៃការគាំទ្រដែលបានស្នើសុំដ៏ធំបំផុត) ហើយនេះរួមទាំងការស្នើសុំការបណ្តុះបណ្តាល និងការគាំទ្រដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងការត្រួតពិនិត្យគុណភាពទឹក។

**អនុសាសន៍÷** កម្មវិធីបណ្តុះបណ្តាលដែលមានស្រាប់ និងថ្មី (រួមទាំងការបណ្តុះបណ្តាលជាផ្លូវការ ការជួយណែនាំ និងការរៀនពីស្ត្រីដូចគ្នា ជាឧទាហរណ៍) ដែលគិតគូរដល់ភាពខុសគ្នានៃយេនឌ័រ ដូចជាកិច្ចការថែទាំកូន ការប្រឈមផ្នែកហិរញ្ញវត្ថុ និងសេរីភាពនៃការធ្វើដំណើរមានកម្រិត គឺជាតម្រូវការ។ នេះអាចជាវគ្គ

បណ្តុះបណ្តាលនៅថ្នាក់តំបន់ ដើម្បីធ្វើឲ្យមានភាពងាយស្រួលដល់សហគ្រិនទាំងឡាយជាស្ត្រីចូលរួម និងគាំទ្រសម្រាប់សមាជិកគ្រួសារចូលរៀនជាមួយគ្នា។

៧. **ការគាំទ្រដល់សហគ្រិនទាំងឡាយ ពីប្តី គ្រួសារ មិត្តភ័ក្តិ និងបណ្តាញទំនាក់ទំនងផ្ទាល់ខ្លួន** ត្រូវបានរកឃើញថាជាការជួយដ៏សំខាន់មួយសម្រាប់ការគាំទ្រពួកគាត់ ដើម្បីបង្កើតសហគ្រាសទឹកស្អាត។
**អនុសាសន៍÷** អង្គការសង្គមស៊ីវិល សមាគម និងរាជរដ្ឋាភិបាល អាចឲ្យបុរស (ជាពិសេស ប្តី) ចូលរួមលើកកម្ពស់ និងចំណាយពេលជាមួយសហគ្រិនទាំងឡាយជាស្ត្រីដែលដឹកនាំសហគ្រាសទឹកស្អាត ទទួលស្គាល់សារៈសំខាន់នៃគ្រួសារនៅក្នុងជំនួញទាំងនេះ និងធ្វើការអភិវឌ្ឍន៍លើមូលដ្ឋានទំនាក់ទំនង និងប្រព័ន្ធគាំទ្រដែលមានស្រាប់សម្រាប់ស្ត្រី។

៨. ជាទូទៅសហគ្រិនទាំងឡាយបានរាយការណ៍ថា ពួកគាត់**លើកទឹកចិត្តស្ត្រីដទៃទៀត ដើម្បីបង្កើតប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត** បើពួកស្ត្រីទាំងនោះបានមានលទ្ធភាពទទួលបាននូវពត៌មាន និងហិរញ្ញវត្ថុរួចហើយ។ សហគ្រិនមួយចំនួនក៏បានកត់សម្គាល់ថា ពួកគាត់អាចផ្តល់ការគាំទ្រ និងការណែនាំរបស់ពួកគាត់ដល់ស្ត្រីដទៃទៀត។ ឯករាជ្យផ្នែកហិរញ្ញវត្ថុ និងការជម្រុញទឹកចិត្តផ្នែកសង្គម (ឧទាហរណ៍ៈ ការផ្តល់ជាវិភាគទានដល់ការធ្វើឲ្យប្រសើរឡើងផ្នែកសុខភាពរបស់សហគមន៍) គឺជាការនាំមុខដ៏សំខាន់សម្រាប់សហគ្រិនទាំងឡាយដែលបានចូលរួមនៅក្នុងការសិក្សានេះ។
**អនុសាសន៍÷** គាំទ្រការរៀនសូត្ររវាងម្ចាស់សហគ្រាសទឹកស្អាត និងបុគ្គលិក និងដោយអាចធ្វើទៅបាន គឺគាំទ្រស្ត្រីដើម្បីភ្ជាប់ទំនាក់ទំនងជាមួយគ្នា និងរៀនពីគ្នាទៅវិញទៅមក។ អ្នកពាក់ព័ន្ធទាំងឡាយនឹងត្រូវកត់សម្គាល់ថា មិនបន្ថែមបន្ទុកជាពេលវេលាសម្រាប់ស្ត្រីទេ ដូច្នេះ ការគាំទ្របែបនេះក៏ជាការផ្តល់ធនធាន និងការគាំទ្រដល់គ្រួសារ និងជាការទទួលខុសត្រូវរបស់សហគ្រាស ដែលត្រូវគិតគូរ។

## តម្រូវការនៃការស្រាវជ្រាវបន្ថែម

ចំណែកឯ ការសិក្សានេះ គឺជាការសិក្សាមួយក្នុងចំណោមការសិក្សាដំបូង ដើម្បីពិនិត្យមើលនូវការប្រឈម និងការជួយដែលទទួលបានបទពិសោធន៍តាមរយៈសហគ្រិនទឹកស្អាតទាំងឡាយជាស្ត្រី និងរបៀបដែលបទដ្ឋានយេនឌ័រមានឥទ្ធិពលទៅលើការប្រឈម និងការជួយទាំងនេះ ការខ្វះចន្លោះចំណេះដឹងបន្ថែម ក៏ត្រូវបានកំណត់ផងដែរ។ ដូច្នេះ ការស្រាវជ្រាវបន្ថែម ត្រូវធ្វើដូចខាងក្រោមនេះ÷

### ការស្រាវជ្រាវដែលពាក់ព័ន្ធទៅនឹងយេនឌ័រ

- កិច្ចការដែលទទួលបានប្រាក់ និងកិច្ចការដែលមិនទទួលបានប្រាក់ៈ ការពាក់ព័ន្ធរវាងបន្ទុកទ្វេនៃកិច្ចការផ្ទះ (រួមទាំងការថែទាំកូន) និងរបៀបដែលបន្ទុកទ្វេនៃកិច្ចការផ្ទះនេះមានឥទ្ធិពលទៅលើការគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងឥទ្ធិពលអវិជ្ជមានអាចត្រូវបានកាត់បន្ថយយ៉ាងដូចម្តេច ដោយអ្នកពាក់ព័ន្ធទាំងឡាយ (ពីថ្នាក់ជាតិ ដល់គ្រួសារ)។

- ផ្នែកហិរញ្ញវត្ថុៈ ផលប្រយោជន៍ផ្សេងៗផ្នែកហិរញ្ញវត្ថុ (ឬការខាតបង់) ដែលទទួលបានបទពិសោធន៍តាមរយៈសហគ្រិនទឹកស្អាតទាំងឡាយជាស្ត្រី  និងផលប្រយោជន៍ទាំងនេះខុសពីសហគ្រិនទឹកស្អាតដទៃយ៉ាងដូចម្តេច។ បានរាយការណ៍អំពីកម្ចីមានអត្រាការប្រាក់ខ្ពស់ ដែលបានដកចេញដោយសហគ្រិនទាំងឡាយ និងថាតើមានឥទ្ធិពលផ្អែកលើយេនឌ័របានពាក់ព័ន្ធឬអត់ ដែលកម្រិតស្ត្រី ដើម្បីទទួលបានកម្ចីមានការប្រាក់ទាប។
- តម្រូវការការបណ្តុះបណ្តាលៈ តើប្រភេទនៃការបណ្តុះបណ្តាលបច្ចេកទេសអ្វីខ្លះ ដែលត្រូវការដោយសហគ្រិនជាស្ត្រី  ការពិចារណាអំពីការប្រឈមទាំងឡាយដែលពាក់ព័ន្ធទៅនឹងយេនឌ័រ ដែលអាចរារាំងស្ត្រីពីការទទួលបាននូវឱកាសនៃការបណ្តុះបណ្តាល។
- បណ្តាញការងារៈ ផលប្រយោជន៍ដែលជាសក្តានុពលនៃវេទិកាសម្រាប់ស្ត្រី ឬបណ្តាញការងារសម្រាប់សហគ្រិនជាស្ត្រី ដើម្បីចែករំលែកបទពិសោធន៍ និងគាំទ្រគ្នាទៅវិញទៅមក បន្ថែមលើយន្តការគាំទ្រដែលមានស្រាប់ ដែលផ្តល់ដោយសមាគមទឹកស្អាតកម្ពុជា និងរាជរដ្ឋាភិបាលនៅថ្នាក់ខេត្ត។

## ការស្រាវជ្រាវដែលពាក់ព័ន្ធទៅនឹងសហគ្រាស

- ការប្រឈមបណ្តាលមកពីរាជរដ្ឋាភិបាល និងច្បាប់ៈ រួមមានការកម្រិតលើតម្លៃទឹក និងតម្រូវការផ្នែករដ្ឋបាលដែលពិបាក ហើយតើការប្រឈមទាំងនេះមានឥទ្ធិពលដល់ការគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតយ៉ាងដូចម្តេច។
- ការបង្កើតតម្រូវការៈ សក្តានុពលសម្រាប់ការទំនាក់ទំនងនៃការផ្លាស់ប្តូរអាកប្បកិរិយា ដើម្បីមានឥទ្ធិពលលើតម្រូវការសម្រាប់សេវាទឹកស្អាត។
- ការពង្រីកសេវាៈ ជម្រើសសម្រាប់តភ្ជាប់ខ្នងផ្ទះដែលស្ថិតនៅក្នុងតំបន់ដាច់ស្រយាល ទៅចូលក្នុងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ហើយតើសហគ្រិនទាំងឡាយអាចត្រូវបានគាំទ្រប្រសើរបំផុតយ៉ាងដូចម្តេច ដើម្បីពង្រីកប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត (រួមទាំងការពិចារណានូវជម្រើសផ្សេងៗ តាមរយៈគំរូទាំងឡាយនៃការគ្រប់គ្រងផ្សេងៗ)។

### អំពីអ្នកនិពន្ធ

វិជ្ជាស្ថានសម្រាប់អនាគតស្ថេរភាព (អាយអេសអេហ្វ - ISF) បានបង្កើតឡើងដោយសកលវិទ្យាល័យបច្ចេកវិជ្ជាស៊ីតនី (យូធីអេស - UTS) ដើម្បីធ្វើការជាមួយផ្នែកឧស្សាហកម្ម/ក្រុមហ៊ុន រដ្ឋាភិបាល និងសហគមន៍ដើម្បីធ្វើការអភិវឌ្ឍន៍អនាគតឲ្យមានស្ថេរភាព តាមរយៈការស្រាវជ្រាវ និងការពិគ្រោះគ្នា។ បេសកកម្មរបស់យើងគឺដើម្បីធ្វើឲ្យមានការផ្លាស់ប្តូរ ឆ្ពោះទៅអនាគតឲ្យមានស្ថេរភាព ដែលការពារ និងធ្វើឲ្យប្រសើរឡើងនូវបរិស្ថានសុខមាលភាពរបស់មនុស្ស និងសមភាពសង្គម។

## ការទទួលស្គាល់

ស្ថាប័នដែលដឹកនាំការស្រាវជ្រាវ (អាយអេសអេហ្វ យូធីអេស - ISF-UTS ) សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការចូលរួមវិភាគទានដ៏ធំធេង របស់ក្រុមស្រាវជ្រាវ រួមទាំងសមាជិកទាំងឡាយពីអង្គការអ៊ីសមីតវេសត៍ និងសមាគមទឹកស្អាតកម្ពុជា។ ជាពិសេស សូមថ្លែងអំណរគុណចំពោះ លោក អ៊ីវ ប៊ុនធឿន លោក គឹម ហ៊ា លោកស្រី ស្ដើង ករុណា លោកស្រី តារា ហៀល និងលោកស្រី ជចជា ដាវីស ពីអង្គការអ៊ីសមីតវេសត៍ និង លោក ដែក វិមានភក្ដី កញ្ញា ខាត់ ដាវី និងលោក សែត សម្បត្តិ ពីសមាគមទឹកស្អាតកម្ពុជា។

ក្រុមស្រាវជ្រាវទាំងអស់គ្នា ក៏សូមថ្លែងអំណរគុណដល់ក្រុមប្រឹក្សាឃុំ មន្ត្រីថ្នាក់ខេត្ត និងមន្ត្រីថ្នាក់ជាតិ ដែលពាក់ព័ន្ធទាំងអស់ និងអ្នកដែលបានសម្ភាសន៍ទាំងអស់ ដែលពាក់ព័ន្ធទៅនឹងគម្រោងនេះ និងជាពិសេស សហគ្រិនទាំងឡាយជាស្ត្រី ដែលបានផ្ដល់ពេលវេលារបស់ពួកគាត់យ៉ាងសប្បុរស ដើម្បីចូលរួមនៅក្នុងការសម្ភាសន៍ និងបានចែករំលែកបទពិសោធន៍ និងការយល់ដឹងរបស់ពួកគាត់ ដែលជាសហគ្រិនទឹកស្អាតទាំងឡាយនៅក្នុងប្រទេសកម្ពុជា។

ការស្រាវជ្រាវនេះ ត្រូវបានផ្ដល់ជាមូលនិធិពីរដ្ឋាភិបាលអូស្ត្រាលី - ក្រសួងការបរទេស និងពាណិជ្ជកម្ម។

សម្រាប់ពតិមានបន្ថែម សូមមើល: http://enterpriseinwash.info/